# ការធ្វើតេស្តពោះវៀន សាមញ្ញមួយអាច សង្គ្រោះជីវិតរបស់ អ្នក



កញ្ចប់ធ្វើតេស្តនៅផ្ទះគឺសម្រាប់មនុស្សដែលមាន អាយុ 45 ឆ្នាំ ដល់ 74 ឆ្នាំ។ វាឥតមានគិតថ្លៃ ងាយធ្វើ និងអាចឃើញ សញ្ញាដំបូងនៃជំងឺមហារីកពោះវៀន។

សួរវេជ្ជបណ្ឌិតរបស់អ្នកសម្រាប់ព័ត៌មាន បន្ថែម។

**www.health.gov.au/nbcsp**

Australian Government

NATIONAL BOWEL CANCER SCREENING PROGRAM

# កម្មវិធីថ្នាក់ជាតិក្នុងការឆ្លុះពិនិត្យមើលជំងឺមហារីកពោះវៀន (The National Bowel Cancer Screening Program)

**ការធ្វើតេស្តពោះវៀនសាមញ្ញមួយអាចសង្គ្រោះជីវិតរបស់អ្នក។ វាងាយជាងការដែលអ្នក អាចនឹកស្មាន។ ពលរដ្ឋអូស្ត្រាលីប្រមាណ 2.5 លាននាក់ធ្វើតេស្តវាជារៀងរាល់ឆ្នាំ។**

អាយុគឺជាកត្តាហានិភ័យធំជាងគេ។ ដូច្នេះ សូម្បីតែមនុស្សដែលមានរាងកាយមាំមួន និងមានសុខភាពល្អក៏គួរធ្វើតេស្តនោះដែរ។

ចាប់ពីអាយុ 45 ឆ្នាំទៅ ហានិភ័យនៃជំងឺ មហារីកពោះវៀនរបស់អ្នកកើនឡើង ហើយជួនកាលរោគសញ្ញានៅស្ងប់ស្ងាត់។

នោះហើយដែលការធ្វើតេស្តឆ្លុះពិនិត្យមើល ឈានចូលមក។ ការធ្វើតេស្តនោះគឺពិនិត្យរកមើលដានតូចៗនៃឈាមនៅក្នុងលាមករបស់អ្នក ដែលអាច ជាសញ្ញាដំបូងនៃជំងឺនោះ។

ដូច្នេះកុំប៉ាន់ស្មានទាបពេកលើឥទ្ធិពលនៃលាមករបស់អ្នក វាអាចសង្គ្រោះជីវិតរបស់អ្នក។

## ចូរធ្វើតេស្ត។ អ្នកទំនងជាបានជោគជ័យ។



**90%**

នៃជំងឺមហារីកពោះវៀនទាំងឡាយអាចព្យាបាលប្រកបដោយជោគជ័យ ប្រសិនបើ ឆាប់រកឃើញ។

## ហេតុអ្វីបានជាត្រូវធ្វើតេស្ត

ប្រទេសអូស្ត្រាលីមានអត្រាខ្ពស់បំផុតមួយក្នុងចំណោមអត្រាខ្ពស់បំផុតនានា នៃជំងឺមហារីកពោះវៀននៅក្នុងពិភពលោក។ ដំណឹងល្អគឺថា ប្រសិនបើឆាប់រកឃើញ នោះជាង 90% នៃ ជំងឺមហារីកពោះវៀនអាចព្យាបាលប្រកបដោយជោគជ័យ។ ការធ្វើតេស្តសាមញ្ញនេះ គឺ ឥតមានគិតថ្លៃ ងាយធ្វើ ហើយអាចសង្គ្រោះជីវិតរបស់អ្នក។ ប្រមូលសំណាកលាមក តូចៗពីរដុំ ដាក់វាផ្ញើតាមប្រៃសណីយ៍ ហើយជា ការស្រេច។

## អ្នកណាខ្លះគួរធ្វើតេស្តនោះ

ដំបូន្មានវេជ្ជសាស្ត្រស្នើឱ្យមនុស្សដែលមានអាយុពី 45 ឆ្នាំ ដល់ 74 ឆ្នាំ ដែលគ្មានរោគសញ្ញា ធ្វើតេស្តរៀងរាល់ពីរឆ្នាំម្តង។ ការធ្វើតេស្តនេះ ជួយឲ្យឆាប់រកឃើញការប្រែប្រួលនៃពោះវៀន ដែលពេលនោះវាងាយព្យាបាលជាង។

## ការធ្វើតេស្តស្វែងរកអ្វីខ្លះ

ការធ្វើតេស្តនោះពិនិត្យរកមើលដានតូចៗនៃឈាមនៅក្នុងលាមករបស់អ្នក ដែលជួនកាល អាចមើលនឹងភ្នែកមិនឃើញ។ ឈាមអាច លេចចេញពីជំងឺមហារីកពោះវៀន ឬដុំឫសដូង (ដុំតូចៗ) ដែលរីកដុះនៅក្នុងស្រទាប់ខាងក្នុង នៃពោះវៀន។ មិនគ្រប់តែដុំឫសដូងទាំងអស់ សុទ្ធតែក្លាយទៅជាជំងឺមហារីកទេ។ ការដក យកដុំឫសដូងទាំងឡាយចេញ កាត់បន្ថយហានិភ័យនៃជំងឺមហារីកពោះវៀនរបស់អ្នក។

## រោគសញ្ញានានា

ជំងឺមហារីកពោះវៀនអាចកើតមានឡើងដោយគ្មានរោគសញ្ញាអ្វីទេ។ ដូចនេះហើយបានជាវា សំខាន់ដែលអ្នកត្រូវធ្វើតេស្តរបស់អ្នកដែលឥតគិតថ្លៃរៀងរាល់ពីរឆ្នាំម្តង។

រោគសញ្ញានានា អាចរួមមាន៖

- មានឈាមនៅក្នុងលាមករបស់អ្នក ឬនៅក្នុងចានបង្គន់
- ការប្រែប្រួលនៃទម្លាប់ទៅបង្គន់របស់អ្នក ដូចជាលាមកកាន់តែទន់ ការទល់លាមក ធ្ងន់ធ្ងរ និង/ឬត្រូវជុះជារឿយៗជាងធម្មតា
- ឈឺក្រពះ
- មានអារម្មណ៍នឿយហត់ដោយគ្មានមូលហេតុ
- ការស្រកទម្ងន់ដោយគ្មានមូលហេតុពន្យល់បាន។

ប្រសិនបើអ្នកមានរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំងនេះ វាមិនមានន័យថា អ្នកមានជំងឺមហារីកពោះវៀននោះទេ ប៉ុន្តែជាការសំខាន់អ្នកត្រូវពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នកឱ្យបានឆាប់ដែលអាចធ្វើទៅបាន។

ជំងឺមហារីកពោះវៀនអាចប៉ះពាល់ដល់មនុស្សដែលមានអាយុក្រោម 45 ឆ្នាំ។ ធ្វើយ៉ាងណាឱ្យប្រាកដថា គ្រួសារ និងមិត្តភក្តិ របស់អ្នកដឹងពី រោគសញ្ញាទាំងនេះ និង លើកទឹកចិត្តឱ្យពួកគេ ពិភាក្សាជាមួយ វេជ្ជបណ្ឌិតរបស់ពួកគេ ប្រសិនបើពួកគេ មានការព្រួយបារម្ភ។



មនុស្សដែលមានអាយុ 45 ឆ្នាំ ដល់ 49 ឆ្នាំ អាចស្នើសុំកញ្ចប់ឆ្លុះពិនិត្យមើលពោះវៀននៅឯ

www.ncsr.gov.au/boweltest។

មនុស្សដែលមានអាយុ 50 ឆ្នាំ ដល់ 74 ឆ្នាំ ទទួលបានកញ្ចប់ឆ្លុះពិនិត្យមើលពោះវៀននៅក្នុងប្រអប់សំបុត្រជារៀងរាល់ 2 ឆ្នាំម្តង។

អ្នកក៏អាចសួរវេជ្ជបណ្ឌិតរបស់អ្នកអំពីការទទួលបានកញ្ចប់នេះផងដែរ។

www.ncsr.gov.au
www.health.gov.au/nbcsp
1800 627 701

**សម្រាប់ព័ត៌មានជាភាសារបស់អ្នក**

សូមទូរសព្ទទៅ សេវាបកប្រែភាសាសរសេរ និងបកប្រែភាសាផ្ទាល់មាត់ (Translating and Interpreting Service )៖ 13 14 50 ឬចូលមើល www.health.gov.au/nbcsp-translations